


យើងកំពុងស្វែងរកបុគ្គលិកផ្នែក

# គ្រូកីឡា

តើអ្នកស្រឡាញ់ការបង្រៀនកីឡា និងរៀបចំកម្មវិធីសប្បាយៗសម្រាប់កុមារ/យុវវ័យដែរឬទេ?

ប្រសិនជាអ្នកឆ្លើយថា "ចាស/បាទ" នោះអ្នកអាចជាអ្នកដែលយើងត្រូវការ។

**ការពណ៌នាអំពីអ្វីដែលអ្នកគួរមាន៖**

- មានបទពិសោធន៍ផ្នែកកីឡា និងមានជំនាញក្នុងការបង្រៀន
- មានគំនិតច្នៃប្រឌិត ដើម្បីទាក់ទាញកុមារ និងយុវជន តាមរយៈសកម្មភាពកីឡា និងកម្មវិធីសិល្បៈកំសាន្ត
- អត្តចរិកល្អ ម៉ឺងម៉ាត់ ម៉តចត់ ចេះអត់ធ្មត់ រួសរាយរាក់ទាក់ រហ័សរហួន និងអាចធ្វើការជាក្រុមបានល្អ
- ចូលចិត្តធ្វើការជាមួយកុមារ និងយុវវ័យ
- មានបទពិសោធន៍ទំនាក់ទំនងសាធារណៈ

**ទំនួលខុសត្រូវ ៖**

- រៀបចំសកម្មភាពក្នុងក្លឹបហ្វ្រេនឲ្យត្រូវជាមួយកាលវិភាគបណ្តុះបណ្តាលវិជ្ជាជីវៈ និងមណ្ឌលអប់រំរបស់អង្គការមិត្តសំឡាញ់
- ដឹកនាំក្រុមកុមារ យុវវ័យ បង្កើតសកម្មភាពកីឡា ផ្នែកខ្លះនៃសិល្បៈ និងកម្មវិធីកំសាន្ត
- សម្របសម្រួលកុមារ យុវវ័យ ឲ្យចូលរួមព្រឹត្តិការណ៍ទាំងក្នុង និងក្រៅអង្គការ ដើម្បីអភិវឌ្ឍន៍សមត្ថភាពកុមារ និងយុវវ័យ
- រៀបចំទីកន្លែង និងវេទិការបស់ក្លឹបហ្វ្រេនដើម្បីប្រារព្ធធ្វើកម្មវិធីផ្សេងៗ
- ចូលរួមធ្វើរបាយការណ៍ជូនម្ចាស់ជំនួយ
- រៀបចំផែនការ ប្រចាំសប្តាហ៍ ប្រចាំខែ និងធ្វើបច្ចុប្បន្នភាពរបាយការណ៍វឌ្ឍនភាពប្រចាំខែ

**លក្ខខណ្ឌការងារ និងអត្ថប្រយោជន៍៖**

- ធ្វើការ៦ថ្ងៃក្នុង១សប្តាហ៍
- ថវិកាប្រចាំឆ្នាំ សម្រាប់ចំណាយលើសុខភាពកូន និងមានកន្លែងមើលថែទាំកូន
- បូករួមជាមួយអត្ថប្រយោជន៍ចាំបាច់ទាំងអស់ដូចជា៖ បសស, ប្រាក់សោធន
- ប្រាក់អតីតភាពការងារ ព្រមទាំងប្រាក់លើកទឹកចិត្តប្រចាំឆ្នាំ និង ការឈប់សម្រាកដែលមានប្រាក់ខែ។

**ចាប់អារម្មណ៍?**

សូមផ្ញើប្រវត្តិរូបសង្ខេបរបស់លោកអ្នកដោយដាក់ចំនួន**ប្រាក់ខែដែលអ្នករំពឹងទុក**ទៅកាន់តេលេក្រាម៖

https://t.me/phourngtola ពួកយើងរីករាយនឹងស្តាប់ពីអ្នក!

@PHOURGTOLA

បេក្ខជន ឬបេក្ខនារីទាំងអស់នឹងឆ្លងកាត់ការត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់ទៅលើគោលការណ៍ការការពារកុមារ និងកិច្ចការពារប្រឆាំងនឹងការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ (Beneficiary Protection Policy and PSEA Policy) ។